ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការមូលបត្រកម្ពុជា

លេខ:......៤៩៣.............គ.ម.ក

## សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## ពិធីផ្ទេរតំណែងអគ្គនាយកនៃ គ.ម.ក. និងបំពាក់គ្រឿងឥស្សរិយយស

នៅរសៀលថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៤ បន្ទាប់បានបញ្ចប់កិច្ចប្រជុំគណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក.) លើកទី៣៤ គ.ម.ក. បានប្រារព្ធពិធីផ្ទេរតំណែងអគ្គនាយកនៃ គ.ម.ក. និងបំពាក់គ្រឿងឥស្សរិយយស ក្រោយអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិត អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា។

ជាកិច្ចចាប់ផ្តើម **ឯកឧត្តម ម៉ិញ បានកុសល** បានថ្លែងសុន្ទរកថាស្វាគមន៍ និងរាយការណ៍ពីលទ្ធផលការងាររបស់ គ.ម.ក. ដោយសម្តែងការគោរពដ៏ខ្ពង់ខ្ពស់ និងកតញ្ញូដ៏ជ្រាលជ្រៅបំផុតចំពោះ **ឯកឧត្តមបណ្ឌិត អូន ព័ន្ធមុនីរ័ត្ន**ក៏ដូចជា **ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ គាត ឈន់** អតីតរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលផ្តល់ការទុកចិត្តដល់ឯកឧត្តមក្នុងការបំពេញតួនាទី និងមុខងារជាអគ្គនាយកនៃ គ.ម.ក. ចាប់តាំងពីពេលបដិសន្ធិដាក់ឱ្យដំណើការ គ.ម.ក. គិតរហូតមកដល់បច្ចុប្បន្នអស់រយៈកាល៦ឆ្នាំ។ តាមរយៈការបំពេញការងាររបស់ **ឯកឧត្តម ម៉ិញ បានកុសល** គ.ម.ក. សម្រេចបានការងារជាច្រើនរួមមាន **១.**រៀបចំបទប្បញ្ញត្តិពាក់ព័ន្ធនឹងវិស័យមូលបត្រដូចជាច្បាប់ អនុក្រឹត្យ ប្រកាស និងគោលការណ៍ណែនាំ **២.**ផ្តល់អាជ្ញាបណ្ណ ការអនុញ្ញាត និងទទួលស្គាល់ដល់បុគ្គលមានធុរកិច្ចពាក់ព័ន្ធនឹងវិស័យមូលបត្រ **៣.**រៀបចំការបណ្តុះបណ្តាល **៤.**ប្រលងទទួលស្គាល់គុណវុឌ្ឍិ និងផ្តល់កិច្ចសហប្រតិបត្តិការអន្តរជាតិ **៥.**ពង្រឹងការអនុវត្តច្បាប់ និង **៦.**ទំនាក់ទំនងអន្តរជាតិ ជាដើម។

បន្ទាប់ពីប្រារព្ធពិធីប្រគល់-ទទួលត្រា **ឯកឧត្តម ស៊ូ សុជាតិ** អគ្គនាយកថ្មីនៃ គ.ម.ក. បានថ្លែងអំណរគុណ និងប្តេជ្ញាយ៉ាងមុតមាំក្នុងការខិតខំបំពេញតួនាទី ភារកិច្ចឱ្យទទួលបានជោគជ័យតាមច្បាប់ និងបទប្បញ្ញត្តិដែលមានជាធរមាន ក្នុងគោលដៅអភិវឌ្ឍទីផ្សារមូលបត្រ វិស័យមូលបត្រ ដើម្បីជាចំណែកក្នុងកិច្ចអភិវឌ្ឍសេដ្ឋកិច្ចជាតិ បន្តពង្រឹងវិន័យការងារ តួនាទី និងភារកិច្ចរបស់មន្ត្រីទៅតាមលំដាប់ថ្នាក់ និងសមត្ថកិច្ចក្នុងភាពជានិយ័តករក្នុងវិស័យមូលបត្រ ព្រមទាំងបន្តពង្រឹងបន្ថែមទៀតនូវតួនាទី និងភារកិច្ចរបស់ស្ថាប័ន"គណៈកម្មការមូលបត្រកម្ពុជា" ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា។

នៅក្នុងពិធីដ៏មានសារៈសំខាន់នេះ **ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី** រួមជាមួយសមាជិក សមាជិកាទាំងអស់បានវាយតម្លៃខ្ពស់ និងកោតសរសើរ ព្រមទាំងថ្លែងអំណរគុណចំពោះ **ឯកឧត្តម ម៉ិញ បានកុសល** សម្រាប់ស្នាដៃ និងសមិទ្ធផលដែលបានសម្រេចនាពេលកន្លងមក។ **ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី** បានស្នើឯកឧត្តមអគ្គនាយកថ្មីនៃ គ.ម.ក. ព្រមទាំងអគ្គនាយករងទាំង ៣ រូបនៃ **គ.ម.ក.** ដែលជាថ្នាក់ដឹកនាំបច្ចេកទេស បន្តការដឹកនាំ ដោយផ្អែកលើមូលដ្ឋានដែលមានស្រាប់ និងផ្តោតលើការងារបន្ទាន់ ២ គឺ÷

ទី១- បន្តជំរុញសហគ្រាស ក្រុមហ៊ុន ឱ្យធ្វើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ដើម្បីបង្កើនការជួញដូរនៅលើទីផ្សារឱ្យកាន់តែមមាញឹក និងប្រកបដោយភាពប្រុងប្រយ័ត្ន។

អាសយដ្ឋានបណ្តោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា
Temporary Address: #99 Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia www.secc.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៨៨៥-៦១១ ទូរសារ : ៨៥៥-២៣-៨៨៥-៦២២
Phone : 855-23-885-611 Fax : 855-23-885-622
E-mail : info@secc.gov.kh

ទី២- បន្តពិនិត្យសិក្សា រៀបចំដាក់ឱ្យអនុម័ត និងដាក់ឱ្យអនុវត្ត នូវបទប្បញ្ញត្តិពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្របំណុល ការបោះផ្សាយលក់មូលបត្រដោយសហគ្រាសធុនតូច និងមធ្យមជាដើម ដើម្បីលើកកម្ពស់ប្រតិបត្តិការទីផ្សារ ទំនុកចិត្តរបស់តួអង្គ និងអ្នកចូលរួមទីផ្សារ ក៏ដូចជាវិនិយោគិនសាធារណៈផ្សេងទៀត។

ជាចុងក្រោយ **ឯកឧត្តមបណ្ឌិត អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធាន គ.ម.ក. បានបំពាក់គ្រឿងឥស្សរិយយសដល់ **ឯកឧត្តម ម៉ិញ បានកុសល** និង**ឯកឧត្តម កៅ ថាច** ដែលបានចូលរួមចំណែកក្នុងការបង្កើត និងអភិវឌ្ឍន៍ទីផ្សារមូលបត្រកម្ពុជាតាំងពីដំណាក់កាលដំបូង។

ពិធីផ្ទេរតំណែងអគ្គនាយកនៃ គ.ម.ក. និងបំពាក់គ្រឿងឥស្សរិយយសបានបញ្ចប់នៅម៉ោង ១៨ និង ១៥ នាទី។

**គណៈកម្មការមូលបត្រកម្ពុជា**